# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1444

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងអភិវឌ្ឍន៍ទីក្រុងរណបបៃតង ត្បូងឃ្មុំ និងកណ្តាល

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/24

កាលបរិច្ឆេទបញ្ចប់គម្រោង 01/01/24

៣. ចំណាយគម្រោងសរុប $174,696,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

RESPONSIBLE UNIT Ministry of Land Management, Urban Planning and Construction

អង្គភាពទទួលខុសត្រូវ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការគ្រប់គ្រងដីធ្លី ការធ្វើផែនការ និងការគ្រប់គ្រងទីក្រុង ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អបរិស្ថាន

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

ការជំរុញការទាក់ទាញវិនិយោគ (បរិយាកាសវិនិយោគ និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនិងការរៀបចំតំបន់ឧស្សាហកម្ម)

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី

Land Management

Land Management

Land Management

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កណ្តាល, ត្បូងឃ្មុំ ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលបំណងរយៈពេលវែង៖ 1) កែលម្អ និងពង្រីកបណ្តាញដឹកជញ្ជូន មួយជំហានម្តងៗ ឱ្យសមស្របនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង។ ទន្ទឹមនឹងនោះ វានឹងក្លាយជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍន៍ទីក្រុង ជំរុញការអភិវឌ្ឍពាណិជ្ជកម្ម និងអាជីវកម្មសេវាកម្ម ទាញយកសក្តានុពលទេសចរណ៍ ក៏ដូចជាបង្កើតឱកាសការងារ ដើម្បីបង្កើនប្រាក់ចំណូលរបស់ប្រជាជន និង 2) កែលម្អលក្ខខណ្ឌអនាម័យបរិស្ថាន និងទេសភាពបរិស្ថានទីក្រុង ដែលនឹងធ្វើអោយប្រសើរឡើងនូវសុខភាព និងគុណភាពរស់នៅរបស់ប្រជាជន។

គោលបំណងរយៈពេលខ្លី៖ ១) កែលម្អហេដ្ឋារចនាសម្ព័ន្ធបរិស្ថាន រួមទាំងប្រព័ន្ធលូ ទំនប់ទឹក និងការបូមខ្សាច់ សម្រាប់ការបង្ការទឹកជំនន់ឱ្យបានកាន់តែប្រសើរឡើង។ ការគ្រប់គ្រងការផ្គត់ផ្គង់ទឹក អនាម័យ និងសំណល់រាវ និងធ្វើឱ្យប្រសើរឡើងនូវការធ្វើបន្សុទ្ធកាកសំណល់រឹង ដើម្បីកែលម្អលក្ខខណ្ឌបរិស្ថាន និង ២) ចូលរួមចំណែកក្នុងការកែលម្អទីក្រុងឱ្យកាន់តែស្អាត និងបៃតង និងអភិវឌ្ឍទីក្រុងស្របតាមយុទ្ធសាស្ត្រជាតិស្តីពីកំណើនបៃតង។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងអភិវឌ្ឍន៍ទីក្រុងរណប (SCDP)

គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បី "ធ្វើឱ្យទីក្រុងមានបរិយាប័ន្ន សុវត្ថិភាព ភាពធន់ និងនិរន្តរភាព"។ គម្រោងនេះនឹងអភិវឌ្ឍទីក្រុងប្រកួតប្រជែងបៃតង និងមានបរិយាប័ន្ន សម្រាប់ខេត្តត្បូងឃ្មុំ និងកណ្តាល តាមរយៈ (i) ការពង្រឹងដំណើរការរៀបចំផែនការទីក្រុង (ii) ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធបៃតង និងធន់នឹងអាកាសធាតុ និង (iii) ការកែលម្អប្រសិទ្ធភាព និងនិរន្តរភាពស្ថាប័ន។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ការអភិវឌ្ឍទីក្រុងបៃតងជុំវិញទីក្រុងធំៗនៃខេត្តទាំងពីរ គឺខេត្តត្បូងឃ្មុំ និងខេត្តកណ្តាល នឹងធ្វើឱ្យការតភ្ជាប់បណ្តាញបៃតងកាន់តែប្រសើរឡើងសម្រាប់តំបន់កណ្តាលនៃខេត្តធំៗទាំងនោះ។ បច្ចុប្បន្ននេះ មានការពន្លឿនទីក្រុងរណបជុំវិញទីក្រុងចាស់ ដែលអាចឱ្យទីក្រុងកណ្តាលកើនកំដៅខ្លាំង ដូច្នេះវាជាកង្វល់ដ៏ធំមួយក្នុងការជៀសវាងបញ្ហានេះ។ តាមរយៈការបង្កើតទីក្រុងឆ្លាតវៃ និងបៃតងជុំវិញកន្លែងកណ្តាល ទីក្រុងសំខាន់ និងរណបទាំងនោះ នឹងមានបរិយាប័ន្ន សុវត្ថិភាព ភាពធន់ និងនិរន្តរភាពនាពេលអនាគត។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់គ្រួសារ បុគ្គល ក្រុមហ៊ុន ស្ថាប័នឯកជន ឬសាធារណៈ ដោយ (i) ធ្វើឱ្យស្តង់ដារនៃការរស់នៅរបស់ខ្លួនមានភាពប្រសើរឡើង 2)មានសិទ្ធិ ប័ណ្ណកម្មសិទ្ធិ ឬការប្រាក់លើផ្ទះ ដីណាមួយ (រួមទាំងលំនៅដ្ឋាន ពាណិជ្ជកម្ម កសិកម្ម ព្រៃឈើ សាលារៀន និងហេដ្ឋារចនាសម្ព័ន្ធសង្គមសាធារណៈ ផ្សេងទៀតនឹងកាន់តែប្រសើរឡើង។) (iii) មានធនធានទឹក ចលនវត្ថុ ឬអចលនវត្ថុផ្សេងទៀតដែលទទួលបាន កាន់កាប់ កម្រិត ឬទទួលបានការកែលម្អ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះអាចស្ថិតក្នុងប្រភេទ A និង B ដូច្នេះផលប៉ះពាល់សង្គម និងបរិស្ថានត្រូវបានសិក្សាក្នុងអំឡុងពេលសិក្សាសមិទ្ធិលទ្ធកម្ម (feasibility study)។ គម្រោងនេះអាចពាក់ព័ន្ធនឹងផែនការតាំងទីលំនៅថ្មី (RP) សម្រាប់សកម្មភាពទាំងអស់ក្រោម "គម្រោងទីក្រុងបៃតង" ក្នុងខេត្តត្បូងឃ្មុំ និងកណ្តាល ដូច្នេះហើយ វាគឺដើម្បីរៀបចំ និងសិក្សាដើម្បីអនុលោមតាមគោលនយោបាយគាំពារសង្គមរបស់ម្ចាស់ជំនួយ។ ក្នុងដំណាក់កាលនៃការអនុវត្តគម្រោង RPs នឹងត្រូវបានធ្វើបច្ចុប្បន្នភាពដោយការគ្រប់គ្រងគម្រោង ស្របតាមការរចនាបច្ចេកទេសលម្អិត និងដំណាក់កាលសាងសង់នៃធាតុផ្សំនីមួយៗ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| ៤. **ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដោយបានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ** | 50 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ទាក់ទងនឹងគោលនយោបាយជាតិយេនឌ័របច្ចុប្បន្ន គម្រោងនេះមានគោលបំណងឱ្យមានការចូលរួម 40% នៃស្ត្រីនៅគ្រប់កម្រិតនៃគម្រោង។ ស្ត្រីអាចធ្វើការក្នុងការគ្រប់គ្រងគម្រោង គណៈកម្មាធិការប្រឹក្សា ក្នុងអំឡុងពេលអនុវត្តគម្រោង និងក្នុងអំឡុងពេលនៃ feasibility study អាចត្រូវបានជ្រើសរើសជាអ្នកប្រឹក្សា។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**គម្រោងនេះនឹងមានវិស័យសំខាន់ៗចំនួនបី គឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) វិស័យដឹកជញ្ជូន វិស័យរ៉ែ និងថាមពល បរិស្ថាន ហើយនឹងចូលរួមជាមួយថ្នាក់ក្រោមជាតិពីមន្ទីរពាក់ព័ន្ធខេត្តផងដែរ។ វិស័យទាំងនេះមានសមត្ថភាពពេញលេញក្នុងការអនុវត្តគម្រោង។ MLMUPC មានសមត្ថភាពខ្ពស់នៃបុគ្គលិក** [illegible]

២៣. [illegible] អំពីកាពប្រឈមនានា ដែល បណ្តាលឲ្យ [illegible] អនុវត្តគម្រោង ការប្រែប្រួលអាកាសធាតុ និងការធ្វើផែនការនគរូបនីយកម្ម។

**សមត្ថភាពទាំងនេះគឺដូចគ្នានឹងក្រសួងពាក់ព័ន្ធផ្សេងទៀតដែរ។**

គម្រោងនេះស្ថិតនៅក្រោមការស្នើសុំមូលនិធិសម្រាប់ជំនួយបច្ចេកទេសរៀបចំគម្រោង (PPTA) ដើម្បីគូសបញ្ជាក់ពីបញ្ហាសក្តានុពល ធ្វើការសិក្សា feasibility study និងការរចនាលម្អិត។ គម្រោងនេះត្រូវបានស្នើឡើងដើម្បីចាប់ផ្តើមនៅឆ្នាំ 2023 ប្រសិនបើមានការផ្តល់មូលនិធិ។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះត្រូវបានស្នើហិរញ្ញប្បទានទៅ ADB និង World Bank។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 929.0 | 950.0 | 593.0 | 2,472.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 800.0 | 800.0 | 500.0 | 2,100.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 120.0 | 140.0 | 90.0 | 350.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 9.0 | 10.0 | 3.0 | 22.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 503.0 | 10,010.0 | 105,110.0 | 115,623.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 90,030.0 | 90,030.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 500.0 | 10,000.0 | 10,000.0 | 20,500.0 | 0.0 |
| ទិញសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 5,000.0 | 5,000.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 70.0 | 70.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 3.0 | 10.0 | 10.0 | 23.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,432.0 | 10,960.0 | 105,703.0 | 118,095.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 1,432.0 | 10,960.0 | 105,703.0 | 118,095.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: